មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៦-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤២១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ មន្ត្រីរាជការ និងសប្បុរសជន ចំនួន ០៤ រូប ៣៧៤៩

១៩-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤២៣ ស្តីពី ការតម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី **លឹម សុខារស្មី** នាយនគរបាលជាតិជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ ៣៧៥០

១៩-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤២៤ ស្តីពី ការតម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី **ឌុច ដាណា** នាយនគរបាលជាតិជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ ៣៧៥១

១៩-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤២៥ ស្តីពី ការតែងតាំងមន្ត្រីជាន់ខ្ពស់ ចំនួន ០២ រូប ជាទីប្រឹក្សា ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ៣៧៥២

១៩-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤២៦ ស្តីពី ការតម្លើងឋានន្តរស័ក្តិជូន លោក **និន សុខឃួន** ពីឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ ៣ ទៅក្នុង ឋានន្តរស័ក្តិ ឧត្តមមន្ត្រីថ្នាក់លេខ ៤ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ ៣៧៥៣

១៩-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤២៧ ស្តីពី ការតែងតាំងឯកឧត្តម **ហោ ប៉េងហួរ** ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៣៧៥៤

១៩-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤២៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ លោកជំទាវ **ថាយ ម៉ា គង់ សំអុល** ៣៧៥៥

១៩-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤២៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ០៤ រូប ៣៧៥៦

២១-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៣០ ស្តីពី ការផ្តល់ឋានៈជាសាស្ត្រាចារ្យ ជូនដល់មន្ត្រីរាជការដែលមានភារកិច្ចបង្រៀននៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មព្រែកលៀប និង សាលាជាតិកសិកម្មកំពង់ចាម ចំនួន ១៧ រូប ៣៧៥៧

២១-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៣១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ០៧ រូប ៣៧៥៩
២១-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៣២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ លោកស្រី **សិត ណៃសយ** ៣៧៦០
២១-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៣៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ សប្បុរសជន ចំនួន ០៤ រូប ៣៧៦១
២១-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៣៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ប្រគេនចំពោះ ព្រះតេជគុណ **សៀត សុន** ៣៧៦២
២១-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៣៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ និង សប្បុរសជន ចំនួន ២២ រូប ៣៧៦៣

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

១៨-៥-២០១២ -អនុក្រឹត្យលេខ ៧១ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដី ទំហំ ៨.០០០ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកកូនមុំ និង ស្រុករវៀនសៃ ខេត្តរតនគិរី ៣៧៦៤
១៨-៥-២០១២ -អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដី ទំហំ ៧.៧១០ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកស្វាយលើ ខេត្តសៀមរាប ៣៧៦៧
១៨-៥-២០១២ -អនុក្រឹត្យលេខ ៥៧២ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយស ៣៧៧០
១៨-៥-២០១២ -អនុក្រឹត្យលេខ ៥៧៣ អនក្រ.តត ស្តីពី ការតម្លើងថ្នាក់ប្រចាំឆ្នាំ ជូនមន្ត្រីរាជការនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងព្រះបរមរាជវាំង ៣៧៧១
១៨-៥-២០១២ -អនុក្រឹត្យលេខ ៥៧៤ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ៣៧៧២
១៨-៥-២០១២ -អនុក្រឹត្យលេខ ៥៧៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ៣៧៧៤
១៨-៥-២០១២ -អនុក្រឹត្យលេខ ៥៧៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៧៧៧
១៨-៥-២០១២ -អនុក្រឹត្យលេខ ៥៧៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣៧៧៨
១៨-៥-២០១២ -អនុក្រឹត្យលេខ ៥៧៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣៧៧៩
១៨-៥-២០១២ -អនុក្រឹត្យលេខ ៥៧៩ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៣៧៨០
១៨-៥-២០១២ -អនុក្រឹត្យលេខ ៥៨០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣៧៨១

១៨-៥-២០១២ -អនុក្រឹត្យលេខ ៥៨១ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៣៧៨២
១៨-៥-២០១២ -អនុក្រឹត្យលេខ ៥៨២ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣៧៨៣
១៨-៥-២០១២ -អនុក្រឹត្យលេខ ៥៨៣ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៣៧៨៤
១៨-៥-២០១២ -អនុក្រឹត្យលេខ ៥៨៤ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី ៣៧៨៥
១៨-៥-២០១២ -អនុក្រឹត្យលេខ ៥៨៥ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី ៣៧៨៦

២-សេចក្ដីសំរេច

២២-៥-២០១២ -សេចក្ដីសំរេចលេខ ២១ សសរ ស្ដីពី ការប្រកាសកាលបរិច្ឆេទ នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សម្រាប់នីតិកាលទី ៥ នៃរដ្ឋសភា ៣៧៨៧

III-ការងារបណ្ដាក្រសួង

ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០១-៣-២០១១ -លិខិតបញ្ជាក់លេខ ១០៧៩ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ជីន ស៊ី ៣៧៨៩
០១-៣-២០១១ -លិខិតបញ្ជាក់លេខ ១០៨០ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន មេគង្គ ញូ ខនស្ត្រាក់សិន គ្រុប ៣៧៩១
០១-៣-២០១១ -លិខិតបញ្ជាក់លេខ ១០៨១ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អ៊ិនឌ៉ាយរ៉ូខេម ឃែតីថល គ្រុប ៣៧៩៣
០១-៣-២០១១ -លិខិតបញ្ជាក់លេខ ១០៨២ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ស៊ិន យូន ៣៧៩៥
០១-៣-២០១១ -លិខិតបញ្ជាក់លេខ ១០៨៣ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ស៊ីនើជី ឃែតីថល ៣៧៩៧
០១-៣-២០១១ -លិខិតបញ្ជាក់លេខ ១០៨៤ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន តិឌីធី ប្រូឌីធី ៣៧៩៩

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤២១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនត្តយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការ និងសប្បុរសជនចំនួន ០៤រូប ដែលមានគុណបំណាច់យ៉ាងធំធេងក្នុងការបម្រើជាតិមាតុភូមិ

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១- លោក ហួត រិន **២- លោក ព្រឹម រដ្ឋា**
៣- លោក ញ៉ឹត បានខេង **៤- លោកវរសេនីយ៍ត្រី ស៊ុន លីច**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

[illegible]. ១២០៥.៤២៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១២

លេខៈ៣៩៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ៖ [illegible] ឆ្នាំ២០១២
អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤២៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រ្តីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/ ០១៩៦ /០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនលោកឧត្តមសេនីយ៍ត្រី **លឹម សុខារស្មី** អត្តលេខ ១២៩៧២ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

តារសេ. ១២០៥.៤២៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១២

លេខ:៤២៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល
ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤២៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/ ០១៩៦ /០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូនលោកស្រីឧត្តមសេនីយ៍ត្រី **ឌុច ដាណា** អត្តលេខ ៣៣១១១ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស.១២០៥.៤២៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១២

លេខៈ ៤២៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០១២
[illegible]រាជរដ្ឋាភិបាល
សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤២៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៨ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំងមន្ត្រីជាន់ខ្ពស់ចំនួន ០២រូប ដូចមានរាយនាមខាងក្រោម :

១-ឯកឧត្តម **ពុត ជូប** ជាទីប្រឹក្សា ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

២-ឯកឧត្តម **ហេង សម្បត្តិ** ជាទីប្រឹក្សា ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣១៩៩.១២០៥.៤៣០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១២

លេខ: ៤៧៤ ច.ល

សេចក្តីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១២

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី (stamp) **...ទីស្តីការគណៈរដ្ឋាភិបាល**

ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤២៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនត្តយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានដំឡើងឋានន្តរស័ក្តិជូន លោក **ឌិន សុខឃួន** ពីឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ ៣ ទៅឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៤ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរល.១២០៥.៤៣១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១២

លេខ: ៤០៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ឧសភា ឆ្នាំ២០១២
អគ្គលេខាធិការរងទី១ រាជរដ្ឋាភិបាល
សេង សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤២៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម **ហោ ម៉េងហួរ** ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើអនុរដ្ឋលេខាធិការ។

មាត្រា ២: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣១៧.១២០៥.៤៣២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១២

លេខ: ៤២៣០.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៧៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

ចំពោះ

លោកជំទាវ ថាយ ង៉ា គង់ សំអុល

ដែលបានខិតខំបំពេញភារកិច្ចជូនជាតិមាតុភូមិ និងមានស្នាដៃល្អ
ក្នុងការចូលរួមចំណែកកសាងអភិវឌ្ឍន៍ប្រទេសជាតិ

មានលេខ.១២០៥.៤៣៣
បានប្រថាប់ព្រះរាជលញ្ឆករហើយ
ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១២

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ: ០១៥/១២.....រ.ចច
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០១២
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីវង្គារ គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤២៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជនចំនួន ០៤រូប ដែលមានស្នាដៃល្អ និងគុណបំណាច់ជាច្រើន
ក្នុងការចូលរួមចំណែកកសាង និងអភិវឌ្ឍន៍ក្នុងខេត្តកំពង់ឆ្នាំង

នូវ

ក- គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍ :**

១- លោកជំទាវ **មិន រិទ្ធិគុណ**

២- លោកជំទាវ **សុខ នារី**

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា :**

១- ឯកឧត្តម **ចម ប្ញូរិយ**

២- លោកជំទាវ **សុខ បុប្ផា**

នរោត្តមសីហមុនី

ពរ៣.១២០៥.៤៣៤

បានប្រថាប់ព្រះរាជលញ្ឆករហើយ

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១២

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ ......១២...... រ.ចច
រាជធានីភ្នំពេញ ថ្ងៃទី ......ខែ ឧសភា ឆ្នាំ ២០១២
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីធរា គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៣០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានផ្តល់ឋានៈជាសាស្ត្រាចារ្យ ជូនដល់មន្ត្រីរាជការដែលមានភារកិច្ចបង្រៀននៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មព្រែកលៀប និងសាលាជាតិកសិកម្មកំពង់ចាម ចំនួន១៧រូប ៖

១-ឯកឧត្តម **ច័ន្ទ សារុន** បណ្ឌិតផ្នែកវិទ្យាសាស្ត្រកសិកម្ម
២-ឯកឧត្តម **ឌី សុគន្ធ** បណ្ឌិតផ្នែកជីវវិទ្យា
៣-ឯកឧត្តម **ចាន់ ណារ៉ែត** បណ្ឌិតផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ចកសិកម្ម
៤-ឯកឧត្តម **គុំ សារ៉ូន** បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រព្រៃឈើ
៥-ឯកឧត្តម **ឈៅ ធូក** បណ្ឌិតផ្នែកវិទ្យាសាស្ត្រជលផល
៦-ឯកឧត្តម **សៅ ឌីច័ន្ទ** បណ្ឌិតផ្នែកផែនការអភិវឌ្ឍន៍ជនបទ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

៧-ឯកឧត្តម	**ឡោ ស្មើ**	បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រកសិកម្ម
៨-ឯកឧត្តម	**ម៉ែន ស៊ីផាន់**	បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រកៅស៊ូ
៩-ឯកឧត្តម	**ម៉ៅ ប៊ុនថាន**	បណ្ឌិតផ្នែកវិទ្យាសាស្ត្រកសិកម្ម
១០-លោក	**សុក គន្ធី**	បណ្ឌិតផ្នែកវិស្វកម្មកសិកម្ម
១១-លោក	**ម៉ែន សារុម**	បណ្ឌិតផ្នែកវិទ្យាសាស្ត្រកសិកម្ម
១២-លោកស្រី	**សេន ម៉ុំ**	បណ្ឌិតផ្នែកវិទ្យាសាស្ត្រសត្វ
១៣-លោក	**ថៃ ឧត្តម**	បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិស្វកម្មកសិកម្ម
១៤-លោក	**មាស សុទ្ធី**	ថ្នាក់ក្រោយបណ្ឌិតផ្នែកវេជ្ជសាស្ត្រសត្វ
១៥-លោក	**ឈុំ គិតលន់**	បណ្ឌិតផ្នែកវិទ្យាសាស្ត្រសត្វ
១៦-លោកស្រី	**គង់ ត្រីស្នា**	បណ្ឌិតផ្នែកវិទ្យាសាស្ត្រសត្វ
១៧-លោក	**ដាង ហុង**	បណ្ឌិតផ្នែកវិទ្យាសាស្ត្រកសិកម្ម

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត.០៥១២.៤៣៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១២

ស្រេះ ៤០ ៤ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែឧសភា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៣១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ០៧រូប មានគុណបំណាច់ក្នុងការចូលរួម ជួយកសាង អគារសិក្សា ០១ខ្នង មាន ០៥បន្ទប់ និង ព្រះវិហារ វត្តសាមគ្គីគីរីរស្មី ស្ថិតនៅក្នុងភូមិជាំម្លូ ឃុំរការពរប្រាំ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម សម្រេចបានលទ្ធផលល្អ

នូវ

ក-គ្រឿងឥស្សរិយយសសុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍

១- មហាឧបាសក នៅ គន់ ៣- មហាឧបាសក ង៉ិច គីច
២- មហាឧបាសិកា សៅ ចន្ថា ៤- មហាឧបាសិកា ចេង សាំងាន

ខ-គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

១- លោក កែវ នារ្ឫទ្ធិ ៣- លោក ភាំង អេងនាយ
២- លោកស្រី ខួន ចាន់ថា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៣. ១២០៥.៤៣៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២

លេខ: ៤៧៧ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ២០១២
...ចទីស្តីការគណៈរដ្ឋាភិបាល
...សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៣៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

ចំពោះ

លោកស្រី សិត សៃរសយ

ដែលបានចូលរួមជួយកសាង ព្រះវិហារ នៅវត្តល្វៀងមានជ័យ
ស្ថិតនៅក្នុងឃុំល្វៀង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពាល.១២០៥.៤៣៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២

លេខៈ ៥២១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០១២
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៣៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន០៤រូប ដែលបានឧបត្ថម្ភថវិកាចូលរួមជួយកសាងផ្ទះជូនប្រជាពលរដ្ឋឥតស្នាមដែលក្រីក្រ ចំនួន៥៩គ្រួសារ ស្ថិតនៅភូមិប្រធាតុ ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងអភិវឌ្ឍន៍សង្គមជាតិ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

១- FAHAD MOHAMMED ALSHAMERI
២- AYMAN ABDULLAH BOODAI
៣- MOHAMED AHMED FOUAD
៤- លោក សិន រំលី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពាភឆ.១២០៥.៤៣៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២

លេខៈ ៤២០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ ឧសភា ឆ្នាំ២០១២
អគ្គលេខា[illegible]ទីស្តីការរដ្ឋាភិបាល
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៣៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ប្រគេនចំពោះ

ព្រះតេជគុណ សៀក សួន

ព្រះចៅអធិការវត្តជោតិការ៉ាម ដែលបានកសាងសមិទ្ធផលនានា ក្នុងវត្តជោតិការ៉ាម
ឃុំក្តួមសំណរ ស្រុកលើកដែក ខេត្តកណ្តាល

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៤-១២០៥.៤៣៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២

លេខៈ ៤១៤ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ... ឆ្នាំ២០១២
អគ្គលេខាធិការដ្ឋានទីស្តីការគណៈរដ្ឋមន្ត្រី...
សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៣៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងសប្បុរសជន ចំនួន ២២រូប មានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ ក្នុងការចូលរួមជួយកសាង សមិទ្ធផលជាច្រើន ស្ថិតនៅក្នុងឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល ទទួលបានលទ្ធផលល្អប្រសើរ

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ និបមិន្ទ :

១-	ឧត្តមសេនីយ៍ទោ	ចឹម សុផា អត្តលេខ ០៦០៧	៤-	លោក	ចាន់ ស៊ីន
២-	ឧត្តមសេនីយ៍ត្រី	ឆាង សុវណ្ណារិទ្ធ អត្តលេខ ៥៤៨៣១	៥-	លោក	អែល សិទ្ធិត្រីយ៉ា
៣-	វរសេនីយ៍ទោ	អ៊ុយ សោភី អត្តលេខ ០២៣៩៤	៦-	លោក	ឈុំ សំអុល

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

១-	វរសេនីយ៍ទោ	ណយ សុផានរិទ្ធ អត្តលេខ ៥៥៤០១	៩-	លោក	ពូ ពុទ្ធី
២-	វរសេនីយ៍ទោ	គឹម ថាយ អត្តលេខ ០៣៥៣៧	១០-	លោក	គួរ ចិន្តា
៣-	លោក	អ៊ុក សុខា	១១-	លោក	យូ ខូនហេង
៤-	លោក	ខិន ស៊ីដារ៉េត	១២-	លោក	ចាន់ត ចន្ថា
៥-	លោក	យូ សុណារី	១៣-	លោក	ចាន់ សុគី
៦-	លោក	លី ពុទ្ធជារ៉ា	១៤-	វរសេនីយ៍ទោ	ម៉ុង ម៉ូរ៉ា អត្តលេខ ០៩៩៩
៧-	វរសេនីយ៍ទោ	អ៊ុក ញ៉ាន អត្តលេខ ០៥១១១	១៥-	លោក	ម៉ុន សុពុណ្ណ
៨-	លោក	គង់ គូមិន្ទ	១៦-	លោក	ចាំ សុវណ្ណពិសាល

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល-១៥០៥-៤៤០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២

លេខ: ៤១៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

សយ សុខា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧១ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៨.០០០ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកកូនមុំ និងស្រុកអូរជុំ និងស្រុកបឹ្ងនសៃ ខេត្តរតនគិរី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ស ម្រេ ច

មាត្រា១:-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៨.០០០ (ប្រាំបីពាន់) ហិកតា ដែលមានទីតាំងស្ថិតនៅក្នុងស្រុកកូនមុំ និងស្រុកវើនសៃ ខេត្តរតនគិរី ដើម្បីធ្វើការវិនិយោគដាំដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកាលេខ ១០៤/១២ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាខេត្តរតនគិរី ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

មាត្រា២:-

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

មាត្រា៣:-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល :</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ



Name	COOR_X	COOR_Y
A	673835	1513958
B	676845	1517016
C	678544	1520560
D	680243	1523667
E	679661	1527890
F	682039	1530075
G	682088	1532235
H	685680	1530196
I	687937	1531191
J	689515	1534638
K	690996	1535706
L	690437	1538084
M	691238	1542186
N	695146	1539638
O	694515	1542769
P	695389	1543885
Q	696433	1541628
R	698277	1542793
S	700804	1540114
T	697710	1535411
U	697010	1535194
V	694951	1535095
W	696027	1533395
X	693342	1534085
Y	691619	1533004
Z	690613	1530965
A1	689923	1527195
B1	681494	1523675
C1	682935	1522338
D1	678496	1514828
E1	681204	1514836
F1	681189	1512525
G1	680246	1511801
H1	679667	1511606
I1	679549	1510676
J1	679010	1509975
K1	677995	1509979
L1	677994	1513914

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៧.៧១០ ហិកតា ស្ថិតនៅតំបន់ភូមិសាស្ត្រ ស្រុកស្វាយលើ ខេត្តសៀមរាប

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សម្រេច

មាត្រា១:-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៧.៧១០ (ប្រាំពីរពាន់ ប្រាំពីររយដប់) ហិកតា ដែលមានទីតាំងស្ថិតនៅក្នុងឃុំតាសៀម ស្រុកស្វាយលើ ខេត្តសៀមរាប ដើម្បីធ្វើការវិនិយោគដាំដំណាំកៅស៊ូ និងដំណាំកសិឧស្សាហកម្ម ដូចមានក្នុងផែនទី និងនិយាមកាលេខ ០២៣ ខសរ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១២ របស់សាលាខេត្តសៀមរាប ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

មាត្រា២:-

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

មាត្រា៣:-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល :</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

ផែនទី បង្ហាញពីដីកាត់ចេញក្នុងតំបន់ស្នើសុំសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លី យ៉េ រ៉ាប់ប៊ឺរ ខូអិលធីឌី

ស្ថិតក្នុងឃុំតាសៀម ស្រុកស្វាយលើ ខេត្តសៀមរាប



និយាមកាចំណុចគោល

POINT	COOR_X	COOR_Y
A	438626	1507035
B	427988	1509042
C	428000	1513000
D	430000	1513000
E	430028	1520027
F	434872	1523427

និយាមកាចំណុច ដីកាត់

Name	COOR_X	COOR_Y
a	432033	1517408
b	431038	1517408
c	431085	1518914
d	432032	1518914
e	431545	1508401
f	430644	1511905
g	430625	1513638
h	431424	1513638
i	431425	1511918
j	432298	1508626
k	431229	1518914
l	431229	1520370
m	432526	1521495
n	433930	1521463
o	434246	1521263
p	433971	1520355
q	434653	1519051
r	433609	1518309
s	433296	1518863
t	432288	1518222
u	432032	1518220
v	435641	1518205
w	436164	1518179
x	436396	1518682
y	436299	1519319
z	436523	1519501

សញ្ញាសំគាល់

- ចំណុចគោល
- ចំណុចកាត់ចេញ
- ព្រំប្រទល់ខេត្ត
- ព្រំប្រទល់ឃុំ
- ផ្លូវ
- ផ្លូវទឹក

- តំបន់ស្នើសុំ ៧ ៧១០ ហ.ត
- តំបន់ទ្រនាប់ ៦៤៥ ហ.ត
- តំបន់ព្រៃរក្សាទុក ៩៣៥ ហ.ត
- ដីកងរាជអាវុធហត្ថស្រុក ១៥០ ហ.ត
- ដីកងវិស្វកម្ម ៣៩៦ ហ.ត
- ដីផ្លូវ និងប្រាសាទបុរាណ: ៣១៥ ហ.ត
- ដីពាក់ព័ន្ធប្រជាពលរដ្ឋ: ២ ៥១៨ ហ.ត

គម្របព្រៃឈើ ឆ្នាំ២០០៦

- ព្រៃស្រោង : ១ ៥៩៧ ហ.ត
- ព្រៃពាក់កណ្តាលស្រោង : ២ ៦៧៨ ហ.ត
- ព្រៃល្បោះ : ៨ ៣៦១ ហ.ត
- ដីគ្មានគំរបព្រៃ : ៣៣ ហ.ត

សរុប ១២ ៦៦៩ ហ.ត

ផ្ទៃដីមិនកាត់ចេញ :

សរុបផ្ទៃដីកាត់ចេញ ៤ ៩៥៩ ហ.ត ១២ ៦៦៩ ហ.ត - ៤ ៩៥៩ ហ.ត = ៧ ៧១០ ហ.ត



លេខ ...
បានឃើញ និង គោរពជូនលោក
អភិបាលស្រុកមេត្តាពិនិត្យ និងសម្រេច
ស្វាយលើ,ថ្ងៃទី 17 ខែ ... ឆ្នាំ ២០១១
ប្រធានការិយាល័យកសិកម្មស្រុកស្វាយលើ

លេខ ...
បានឃើញ និង គោរពជូនលោក
អភិបាលស្រុកមេត្តាពិនិត្យ និងសម្រេច
តាសៀម,ថ្ងៃទី ... ខែ 12 ឆ្នាំ ២០១១
មេឃុំតាសៀម
ឃុំ រិន

លេខ ...
បានឃើញ និង គោរពជូនឯកឧត្តម
អភិបាលខេត្តមេត្តាពិនិត្យ និងសម្រេច
ស្វាយលើ,ថ្ងៃទី ... ខែ ... ឆ្នាំ ២០១១
អភិបាលស្រុកស្វាយលើ
ហៅ សែន

លេខ ...
បានឃើញ និង គោរពជូនលោក
អភិបាលស្រុកមេត្តាពិនិត្យ និងសម្រេច
ស្វាយលើ,ថ្ងៃទី ... ខែ ... ឆ្នាំ ២០១១
ប្រធានការិយាល័យភូមិបាលស្រុកស្វាយលើ

លេខ ...
បានឃើញ និង គោរពជូនឯកឧត្តម
អភិបាលខេត្តមេត្តាពិនិត្យ និងសម្រេច
សៀមរាប,ថ្ងៃទី ... ខែមករា ឆ្នាំ ២០១២
ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សៀមរាប
សែ សាមុត

លេខ ...
បានឃើញ និង គោរពជូនឯកឧត្តម
អភិបាលខេត្តមេត្តាពិនិត្យ និងសម្រេច
សៀមរាប,ថ្ងៃទី ... ខែ ... ឆ្នាំ ២០១១
ប្រធានមន្ទីរកសិកម្មខេត្តសៀមរាប
ហឿង សុនិត្យា

លេខ ...
បានឃើញ និង ឯកភាព
សៀមរាប,ថ្ងៃទី ... ខែ ... ឆ្នាំ ២០១២
អភិបាលខេត្ត
ស៊ូ ភិរិន្ទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៧៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូន គ្រឿងឥស្សរិយយស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់ គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។
- យោងតាមសំណើរបស់ សម្តេចចៅហ្វាវាំង គង់ សំអុល

សម្រេច

មាត្រា១ : បំពាក់ **គ្រឿងឥស្សរិយយស** និង **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ និងសប្បុរសជន ដែលមានស្នាដៃល្អ និងលះបង់កំលាំងកាយ-ចិត្ត ក្នុងការបំពេញភារកិច្ចបំរើជាតិ មាតុភូមិ និងចំណាយថវិកា សំភារៈ ផ្ទាល់ខ្លួន ក្នុងការចូលរួមកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ ចំនួន ០៩រូប ដូចខាងក្រោម :

ក- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ សេនា :

១- លោក ផលី ធីណា

ខ- មេដាយ មាសការងារ :

១- លោកស្រី ហៃ សុលីណា
២- លោក សុខ ចាន់ស្តា
៣- លោក សុខ ប៊ុលីន
៤- លោកស្រី ម៉ាន់ ចាន់តារ៉ា
៥- កញ្ញា ផល សុម៉ាលី
៦- លោក អាន ម៉េងសែ

គ- មេដាយ ប្រាក់ការងារ :

១- អ្នកស្រី មាស សុចិន្តា

ឃ- មេដាយ សំរិទ្ធការងារ :

១- លោក សាធ កុសល

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវទទួលអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ចម្លងជូន
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៧៧ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការតម្លើងថ្នាក់ប្រចាំឆ្នាំ ជូនមន្ត្រីរាជការ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងព្រះបរមរាជវាំង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រឹត្យលេខ NS/KRT-34 ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងព្រះបរមរាជវាំង ។
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ។

សម្រេច

មាត្រា ១ ៖ ត្រូវបានតម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិវរមន្ត្រី ជូនមន្ត្រីរាជការ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងព្រះបរមរាជវាំង គិតចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១២ តទៅ មានដូចខាងក្រោម ៖

១-លោក	សរ	ចន្ទិរិទ្ធី	ពី វរមន្ត្រី ថ្នាក់លេខ ៧	ទៅ វរមន្ត្រី ថ្នាក់លេខ ៦
២-លោក	ពិន	សារ៉ាត	ពី វរមន្ត្រី ថ្នាក់លេខ ១០	ទៅ វរមន្ត្រី ថ្នាក់លេខ ៩
៣-លោក	ហូ	ឌីណូ	ពី វរមន្ត្រី ថ្នាក់លេខ ១០	ទៅ វរមន្ត្រី ថ្នាក់លេខ ៩
៤-លោក	កាន់	សុវណ្ណា	ពី វរមន្ត្រី ថ្នាក់លេខ ១០	ទៅ វរមន្ត្រី ថ្នាក់លេខ ៩
៥-លោក	ផលើ	ឌីណា	ពី វរមន្ត្រី ថ្នាក់លេខ ១០	ទៅ វរមន្ត្រី ថ្នាក់លេខ ៩
៦-លោក	ឈាហនី	នរតនា	ពី វរមន្ត្រី ថ្នាក់លេខ ១០	ទៅ វរមន្ត្រី ថ្នាក់លេខ ៩

មាត្រា ២ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ចម្លងជូន ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៧៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើត ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៩៣ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

-បានឃើញអនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

-យោងតាមសំណើរបស់ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

សម្រេច

មាត្រា ១ៈ ត្រូវបានតែងតាំងៈ

១-លោក **ខូច មករា** ជាសមាជិកអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន

២-លោក **គី ឡេង** ជាសមាជិកអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន

៣-លោក **អៀង ចន្ថា**	ជាសមាជិកអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន
៤-លោក **ហេង សុខមីណ**	ជាសមាជិកអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន
៥-លោក **ស សំបូរ**	ជាសមាជិកអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** បន្ថែមលើមុខងារបច្ចុប្បន្ន
៦-លោក **គង់ ម៉ារី**	ជាសមាជិកអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើត ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៩៣ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

-បានឃើញអនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

-យោងតាមសំណើរបស់ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

សម្រេច

មាត្រា ១: ត្រូវបានតែងតាំង:

១-លោក **ម៉ៅ បូរាណ** ជាអនុប្រធានផ្នែកសិក្សា និងវិភាគគោលនយោបាយសេដ្ឋកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន

២-លោក **អ៊ឹម សុខធី** ជាអនុប្រធានផ្នែកសិក្សា និងវិភាគគោលនយោបាយសេដ្ឋកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន

៣-លោក **ឡាយ សុខឃៀង** ជាអនុប្រធានផ្នែកសិក្សានិងវិភាគគោលនយោបាយសេដ្ឋកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន

៤-លោក **ខា ម៉េង** ជាអនុប្រធានផ្នែកសិក្សា និងវិភាគគោលនយោបាយសង្គមកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន

៥-លោក **គង់ រដ្ឋា** ជាអនុប្រធានផ្នែកសិក្សា និងវិភាគគោលនយោបាយសង្គមកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន

៦-លោក **ឈឹម សុគន្ធវារៈ** ជាអនុប្រធានផ្នែកសិក្សា និងវិភាគគោលនយោបាយសង្គមកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន

៧-លោកស្រី **ខៀវ វិមល** ជាអនុប្រធានផ្នែកបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន

៨-លោក **លី សែ** ជាជំនួយការឯកឧត្តមប្រធាននឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន

៩-លោក **ម៉ែន វិវឌ្ឍវិទ្យា** ជាជំនួយការឯកឧត្តម **វង្សី វិស្សុត** អនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (ជំនួសលោក **ស៊ីន ចាន់សេរីវុត្ថា** ដែលត្រូវបញ្ចប់ភារកិច្ចដោយបានទទួលភារកិច្ចថ្មី) មានឋានៈស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន

១០-លោក **វង្សី វិចិត្រ** ជាជំនួយការឯកឧត្តម **ចាន់ សុធី** សមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន

